## ការរៀបចំដីដាំ

- ភ្ជួរ ២-៣ដង ហើយរាស់ដីឱ្យម៉ត់ល្អ និង រើសស្មៅ ចេញឱ្យអស់
- បាចកំបោរចំនួន ១ គ.ក្រ លើដី ១០ ម² ភ្ជួរលុបឱ្យបាន ៧ថ្ងៃយ៉ាងតិចមុនដាំម្រះ(ប្រើតែ ១ ដង/ឆ្នាំ)
- រៀបចំរងទំហំ ១ម៉ែត្រ(ត្រូវមានកម្ពស់ ៣០ សម យ៉ាងតិចនៅរដូវវស្សា)
- ពង្រាយជីលាមកគោ និងជីកែង ពេញរងហើយកាប់ប្រចល់ជា មួយ ដីឱ្យសព្វល្អ
- គ្របរងដោយចំបើង(កម្រាស់យ៉ាងតិច ៥ ស.ម) ឬ ផ្លាស់ស្ទិកគ្របដី ដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី ។

## ការបណ្ដុះគ្រាប់

- ត្រាំគ្រាប់ក្នុងទឹកក្ដៅឧណ្ហៗរយៈពេលពី ១៥ ទៅ ២០នាទី
- ពង្រាយគ្រាប់ដែលត្រាំហើយលើក្រណាត់សើម ជក់ទឹករួចមូរក្រណាត់នេះទុកក្នុងកន្លែង ងងឹត
- ត្រូវរក្សាក្រណាត់ដែលបានមូរនោះឱ្យមានសំណើម តែមិនត្រូវឱ្យសើមពេកទេ

ផ្អាប់បាន ២ថ្ងៃ គ្រាប់នឹងបែកមាត់នោះយើងអាចយកវាទៅដាក់បណ្ដុះក្នុងកន្ទោង ឬ ថាសបណ្ដុះបាន ។





## ការបណ្ដុះកូន

- រៀបចំកន្ទោងបណ្ដុះ(ស្លឹកត្នោតឬស្លឹកចេក)ឬថាសបណ្ដុះ
- រៀបចំលាយដីបណ្ដុះ
  - ដីដែលមានជីជាតិ(ដីដំបូក) ១ភាគ
  - ដីកំប៉ុស្ដិ៍ ឬ ជីលាមកគោដែលរលួយ ១ភាគ
  - ផេះអង្កាម(ផេះត្រូវត្រាំទឹកសិនមុននឹងប្រើ)១ ភាគ
- លាយដី ជី ជាមួយផេះអង្កាម ទើបយកទៅលីងឱ្យក្ដៅបំផុត និងទុកឱ្យត្រជាក់ទើបដាក់កន្ទោង
- បណ្ដុះតែ ១ គ្រាប់ក្នុងមួយកន្ទោង គ្រាប់ត្រូវដាក់ផ្ដេកនៅពេលបណ្ដុះ
- ធ្វើដំបូលគ្របពីស្លឹកដូង សំណាញ់កាត់ពន្លឺនៅរដូវក្ដៅតែរដូវវស្សាត្រូវធ្វើដំបូលប្រកផ្លាស់ស្ទិចថ្លា ដើម្បីការពារទឹកភ្លៀង
- ដាក់កូនម្រះឱ្យត្រូវថ្ងៃចំនួន ២ថ្ងៃ មុនដាំ ហើយបន្ថយការស្រោចទឹកដើម្បីឱ្យកូនម្រះរឹងមាំ
- កូនអាយុបាន ៧ ថ្ងៃ អាចយកទៅដាំបាន



**គំរូរៀបចំរងដាំ**








## ការដាំកូនម្រះ

- ស្រោចទឹកកូនម្រះឱ្យសើមល្មម នៅពេលព្រឹកមុនយកទៅដាំ
- ចាប់ផ្ដើមដាំកូនម្រះពីម៉ោង ៣ ល្ងាច ទៅ
- យកកូនម្រះចេញពីកន្ទោង ឬ ថាសបណ្ដុះដោយប្រុងប្រយ័ត្ន បំផុត មិនត្រូវឱ្យដាច់ឬសកូនម្រះឡើយ
- កូនម្រះត្រូវការស្រោចទឹក ឱ្យបានគ្រប់គ្រាន់ជាពិសេសរវាងពី ២-៣អាទិត្យ បន្ទាប់ពីដាំកូនហើយ ។

## ការថែទាំ

ការដាក់ទ្រើងម្រះឱ្យមាំល្អមុនពេលដាំកូន តែមិនត្រូវឱ្យយឺតជាង ៧ ថ្ងៃ បន្ទាប់ពីដាំកូនម្រះទេ ។ពេលដើមម្រះកំពុងលូតលាស់ត្រូវចងវាជាប់ នឹងទ្រើងដើម្បីឱ្យមានទំរទប់ទម្ងន់ដើម ។



| ពេលវេលា | ប្រភេទជី/១ដើម(គុម្ព) | កន្លែងដែលត្រូវដាក់ជី |
|---|---|---|
| មុនដាំ | ជីលាមកសត្វស្ងួត ១.៥ គីឡូក្រាម ជីកែង ១ ស្លាបព្រាបាយ កំពុង (១៥ក្រាម) | ពង្រាយលើរង ហើយកាប់ ច្របល់ជាមួយដី |
| ២ អាទិត្យ បន្ទាប់ពីដាំ | ជីកែង ១ស្លាបព្រាបាយស្មើ(១០ក្រាម) ជីអ៊ុយ រ៉េ ១ ស្លាបព្រាបាយស្មើ (១០ក្រាម) | កប់ជីរាក់ៗ ឆ្ងាយពីគល់ម្រះ កន្លះតឹក |
| ៤ អាទិត្យ បន្ទាប់ពីដាំ | ជីកែង ១ស្លាបព្រាបាយស្មើ(១០ក្រាម)ជីអ៊ុយ រ៉េ ១ ស្លាបព្រាបាយស្មើ (១០ក្រាម) | កប់ជីរាក់ៗ ឆ្ងាយពីគល់ ម្រះ១តឹក |
| ៦ អាទិត្យ បន្ទាប់ពីដាំ | ជីប៉ូតាស្យូម កន្លះស្លាបព្រាបាយ(៥ក្រាម) ជីកែង ១ ស្លាបព្រាបាយស្មើ(១០ក្រាម) | កប់ជីរាក់ៗ ឆ្ងាយពីគល់ម្រះ ១ តឹកកន្លះ |
| **ចាប់ផ្ដើមបេះផ្លែ** | | |
| ៨ អាទិត្យ បន្ទាប់ពីដាំ | ជីកែង ១ ស្លាបព្រាបាយកំពុង(១៥ក្រាម)ជីប៉ូតាស្យូម កន្លះស្លាបព្រាបាយ (៥ក្រាម) | កប់ជីរាក់ៗ ឆ្ងាយពីគល់ម្រះ១តឹកកន្លះ |
| ១០អាទិត្យ បន្ទាប់ពីដាំ | ជីកែង ១ស្លាបព្រាបាយ កំពុង(១៥ក្រាម) | កប់ជីរាក់ៗ ឆ្ងាយពីគល់១តឹកកន្លះ |
| ១២ អាទិត្យ បន្ទាប់ពីដាំ | ជីកែង ១ស្លាបព្រាបាយ កំពុង(១៥ក្រាម) | កប់ជីរាក់ៗឆ្ងាយពីគល់ម្រះ១តឹកកន្លះ |

## ការគ្រប់គ្រងទឹក

- កុំស្រោចទឹកផ្ទាល់ទៅនឹងគល់ម្រះ
- ម្រះជាប្រភេទដំណាំត្រូវការទឹករាល់ថ្ងៃ តែវាមិនត្រូវការដោតជាំពេកទេ ។
- កាលណាសំណើមដីសើមខ្លាំង ធ្វើឱ្យម្រះឆាប់ងាប់ដើម
- ម្រះត្រូវការទឹកច្រើន និង ទៀងទាត់ចាប់ពីម្រះចេញផ្កាឡើងទៅការធ្វើស្មៅត្រូវចាប់ផ្តើម ធ្វើបន្ទាប់ពីដាំកូនបាន ១៤ ថ្ងៃ

## ការគ្រប់គ្រងជម្ងឺ និងសត្វល្អិត

ម្រះច្រើនជួបការបំផ្លាញដោយជម្ងឺសំខាន់ៗនៅរដូវវស្សាជម្ងឺ:

**ជំងឺធុំលឿងស្លឹក:** កើតមានលើស្លឹកនៅក្បែរដីហើយរាលដាលឡើងមកស្លឹក ខាងលើបណ្តាលឱ្យក្តិបម្រះមិនលូតលាស់ស្លឹក មានអុចពណ៌លឿងដែលមានទំហំតូចឬធំ ។ ដើម្បីការពារជម្ងឺនេះយើងត្រូវតែបាញ់ថ្នាំម៉ង់កូស្សែបចំនួន ២ស្លាបព្រាបាយលាយទឹក ១៦ លីត្រ លើកូនពេលមុនដាំ ហើយបន្ទាប់មកត្រូវបាញ់រៀងរាល់អាទិត្យ ។ប្រសិនបើជម្ងឺនេះកើតមានឡើងត្រូវ បន្ថយការស្រោចទឹកនិងស្រោចដីគីមីកាត់ស្លឹកជម្ងឺយកទៅកប់ចោលមុន និង ប្រើប្រាស់ថ្នាំខាងលើ ឱ្យមានប្រសិទ្ធភាព ។



**ចៃ:** ត្រូវឆែករកមើលចៃឱ្យបានញឹកញាប់នៅផ្នែកខាង ក្រោមស្លឹក ។ ចៃបណ្តាលឱ្យស្លឹក និងត្រួយរួញ ។ នៅពេលមាន ពពួកចៃនេះយើងត្រូវកំចាត់វាជាបន្ទាន់ ព្រោះវាជាភ្នាក់ងារចម្លង ជម្ងឺវីរុស ។ វិធានការសម្រាប់កំចាត់ពពួកនេះមានដូចជា:

- កាត់ស្លឹកដែលមានចៃកប់ចោល ឬ ដុត
- ញ្ចេចចៃដោយដៃ
- ប្រើថ្នាំពុលកសិកម្ម
    - អាបាមិចទីនចំនួន១ស្លាបព្រាបាយកន្លះ លាយទឹក ១៦ លីត្រ
    - ឌីណូតហ្វុយរ៉ង(អូស៊ីន)១ កញ្ចប់ទម្ងន់ ៦.៥ក្រាម លាយទឹក ១៦ លីត្រ



ការដាំម្រះច្រើនជួបការបំផ្លាញពីសត្វល្អិតចង្រៃមួយចំនួនដូចជា:

**ស្រាំងទិច ឬ រុយអុចផ្លែ:** ជាប្រភេទរុយទិចផ្លែបញ្ចូល ពងទៅក្នុងក្តិបផ្លែម្រះបន្ទាប់ពីដង្កូវ បានញាស់ក្នុងផ្លែហើយវាធ្វើ ឱ្យផ្លែម្រះទុំមុនពេលប្រមូលផល ហើយរលួយ ។ ការការពារត្រូវ ខ្ចប់ក្តិប ម្រះជាបន្ទាន់ដោយថង់ផ្លាស់ស្ទិច ឬ ក្រដាស់ នៅពេលផ្កា ក្តិបម្រះចាប់ផ្តើមស្រពោន ។ ត្រូវបេះផ្លែដែលខូចៗចេញហើយកប់ ផ្លែទាំងនេះចោលដើម្បីសម្លាប់ដង្កូវនៅក្នុងផ្លែ ។





## ការប្រមូលផល

-ផ្លែម្រះអាចប្រមូលបាននៅពេលដែលក្រឡាផ្លែ រីកល្អ

- យើងអាចប្រមូលផលម្រះជារៀងរាល់ថ្ងៃ ដោយកន្ត្រៃ ឬ កាំបិត នៅពេលព្រឹក
- ប្រមូលផលជាលើកដំបូងបន្ទាប់ពីដាំម្រះបានពី ៤៥ថ្ងៃ ទៅ៥០ថ្ងៃ
-វេចខ្ចប់ផ្លែដែលបេះហើយភ្លាមចូលក្នុងកេះថង់ដែលមានជាតិ ប៉ូលី ហ៊ីឡែន ដើម្បីកុំឱ្យផ្លែរហ័សស្វិត ។



**ការគណនាប្រាក់ចំណាយ និងចំណូលលើផ្ទៃដី ៥00 មែត្រការ៉េ**

| សំភារៈ | ចំណាយ (រៀល) | ប្រាក់ចំណូល | ប្រាក់ចំណេញ |
|---|---|---|---|
| ជីគីមី | ១១៩,000 | | |
| ពូជ | ៤៨,000 | | |
| ជីលាមកគោ | ៣0,000 | | |
| សំណាញ់ទ្រើង | ៤៦,000 | | |
| ឬស្សី | ៣0,000 | | |
| ផ្លាស់ស្ទិចគ្របរង | ១២0,000 | | |
| ថ្នាំកសិកម្ម | ៣0,000 | | |
| ថង់ច្រកផ្លែ | ៥,000 | | |
| ផ្លែបេះសរុបបានចំនួន ១,១៥៨គ.ក | ១,១៥៨គ.ក្រ x ១៤00 រៀល = ១,៦២១,២00 រៀល | | |
| ប្រាក់ចំណេញ | | | ១,១៩៩,២00 |

# ដំណាំម្រះ





giz

EAST-WEST SEED INTERNATIONAL